ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលផ្ទៃប្រព័ន្ធបឹងវាលសំណាបទំហំ ៤ ៨១៥ ហិកតា ស្ថិតក្នុងខេត្តកណ្តាល ជាសម្បត្តិសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៦ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ២០១៦ ស្តីពីការកំណត់ផ្ទៃប្រព័ន្ធបឹងវាលសំណាប ទំហំ ៤ ៨១៥ ហិកតា ស្ថិតក្នុងខេត្តកណ្តាល ជាសម្បត្តិសាធារណៈរបស់រដ្ឋ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ .-**

ត្រូវបានកាត់ផ្ទៃដីទំហំ **១ ២២៨ ហិកតា ៤៨ អា និង ៧០ សង់ទីអា (មួយពាន់ពីររយម្ភៃប្រាំបីហិកតា សែសិបប្រាំបីអា និងចិតសិបសង់ទីអា)** ស្ថិតក្នុងឃុំពាមឧកញ៉ាអុង ឃុំព្រែកក្មេង និងឃុំបារុង ស្រុកល្វាឯម ខេត្តកណ្តាល ដែលបានកំណត់ក្នុងអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ២០១៦ ស្តីពីការកំណត់ផ្ទៃប្រព័ន្ធ



Media from www.moj.gov.kh resource from www.ocm.gov.kh

បឹងវាលសំណាប ទំហំ ៤ ៨១៥ ហិកតា ស្ថិតក្នុងខេត្តកណ្ដាល ជាសម្បត្តិសាធារណៈរបស់រដ្ឋ តាមប្រព័ន្ធកូអរដោនេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទី និងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងចុះបញ្ជីជូនរដ្ឋបាលខេត្តកណ្ដាល។

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តកណ្ដាលត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១ កើត ខែ ពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



Media from www.moj.gov.kh resource from www.ocm.gov.kh

ផែនទីនិងតារាងនិយាមកាខូបសម្ព័ន្ធនៃអនុក្រឹត្យលេខ..................ចុះថ្ងៃទី...២៣...ខែ..............ឆ្នាំ២០២០




តារាងនិយាមកាព្រំដីទំហំ ១ ២២៨ ហិកតា ៤៨ អា ៧០ សង់ទីអា

Projection, UTM, Zone 48N

Datum, WGS 1984

| ID | E | N | ID | E | N |
|---|---|---|---|---|---|
| 1 | 506247.376 | 1278479.177 | 42 | 507772.775 | 1282815.665 |
| 2 | 506242.870 | 1278475.375 | 43 | 508240.090 | 1282811.980 |
| 3 | 506167.893 | 1278412.115 | 44 | 508487.190 | 1282810.030 |
| 4 | 506166.440 | 1278410.889 | 45 | 508662.900 | 1282808.640 |
| 5 | 506090.010 | 1278346.403 | 46 | 508959.916 | 1280629.759 |
| 6 | 506079.724 | 1278337.724 | 47 | 508906.871 | 1280568.359 |
| 7 | 506013.580 | 1278281.917 | 48 | 508841.497 | 1280492.687 |
| 8 | 506010.970 | 1278279.715 | 49 | 508776.122 | 1280417.015 |
| 9 | 505937.150 | 1278217.431 | 50 | 508710.748 | 1280341.344 |
| 10 | 505931.712 | 1278212.843 | 51 | 508645.374 | 1280265.677 |
| 11 | 505860.720 | 1278152.945 | 52 | 508580.000 | 1280190.000 |
| 12 | 505786.888 | 1278090.651 | 53 | 508468.579 | 1280113.930 |
| 13 | 505713.861 | 1278029.035 | 54 | 508385.991 | 1280057.545 |
| 14 | 505631.430 | 1277959.486 | 55 | 508303.404 | 1280001.160 |
| 15 | 505555.000 | 1277895.000 | 56 | 508220.816 | 1279944.775 |
| 16 | 505488.194 | 1277977.976 | 57 | 508138.228 | 1279888.390 |
| 17 | 505428.325 | 1278052.337 | 58 | 508055.640 | 1279832.005 |
| 18 | 505375.871 | 1278117.487 | 59 | 507973.053 | 1279775.620 |
| 19 | 505375.869 | 1278117.490 | 60 | 507890.465 | 1279719.235 |
| 20 | 505653.140 | 1278171.980 | 61 | 507807.877 | 1279662.850 |
| 21 | 505500.270 | 1279193.600 | 62 | 507725.290 | 1279606.465 |
| 22 | 504897.441 | 1279089.101 | 63 | 507642.702 | 1279550.080 |
| 23 | 504865.990 | 1281321.420 | 64 | 507560.114 | 1279493.695 |
| 24 | 504917.410 | 1281326.800 | 65 | 507477.526 | 1279437.310 |
| 25 | 504967.680 | 1281355.910 | 66 | 507394.939 | 1279380.925 |
| 26 | 505020.600 | 1281392.950 | 67 | 507321.608 | 1279330.860 |
| 27 | 505089.390 | 1281461.740 | 68 | 507312.351 | 1279324.540 |
| 28 | 505107.783 | 1281481.971 | 69 | 507229.763 | 1279268.155 |
| 29 | 505111.854 | 1281486.449 | 70 | 507147.175 | 1279211.770 |
| 30 | 505142.310 | 1281519.950 | 71 | 507064.588 | 1279155.385 |
| 31 | 505171.410 | 1281538.470 | 72 | 506982.000 | 1279099.000 |
| 32 | 505221.680 | 1281541.120 | 73 | 506930.740 | 1279055.750 |
| 33 | 505287.830 | 1281517.300 | 74 | 506854.309 | 1278991.264 |
| 34 | 505367.200 | 1281512.010 | 75 | 506777.880 | 1278926.778 |
| 35 | 505412.180 | 1281522.600 | 76 | 506701.450 | 1278862.292 |
| 36 | 505470.390 | 1281543.760 | 77 | 506625.020 | 1278797.806 |
| 37 | 506126.667 | 1281912.951 | 78 | 506548.590 | 1278733.319 |
| 38 | 506744.397 | 1282283.048 | 79 | 506472.160 | 1278668.833 |
| 39 | 506809.806 | 1282479.274 | 80 | 506395.730 | 1278604.347 |
| 40 | 506975.682 | 1282821.956 | 81 | 506319.300 | 1278539.861 |
| 41 | 507583.380 | 1282817.160 | 82 | 506247.380 | 1278479.180 |